# ដំណើរចុងក្រោយ និងដ៏ឯកោរបស់ព្រះអង្គសង្គ្រោះ

**ដោយ ឆាខែល រ្វូដលែញ**
ទស្សនាវដ្ដីសាសនាចក្រ

ពេញមួយជីវិតរមែងស្លាប់របស់ទ្រង់ ព្រះអង្គសង្គ្រោះបានធ្វើដំណើរជាច្រើនដង — ដំណើររបស់ទ្រង់ចេញពីបេថ្លេហិម និងចូលទៅស្រុកអេស៊ីព្ទកាលទ្រង់ជាព្រះឱរស ការធ្វើដំណើររយៈពេល ៤០ ថ្ងៃរបស់ទ្រង់នៅក្នុងទីរហោស្ថាន ការធ្វើដំណើរជាច្រើនដងរបស់ទ្រង់ចូលទៅក្នុងទីក្រុង ភូមិ និងផ្ទះសម្បែងនានាដើម្បីបង្រៀន ព្យាបាល និងប្រទានពរដល់គេអំឡុងពេលការបម្រើរបស់ទ្រង់ និងការធ្វើដំណើរជាច្រើនផ្សេងទៀត ។ ប៉ុន្តែមានការធ្វើដំណើរមួយដែលព្រះអង្គសង្គ្រោះបានប្រឈមមុខតែអង្គឯង ហើយវាជាដំណើរដែលមានតែទ្រង់ប៉ុណ្ណោះទើបអាចស៊ូទ្រាំនឹងវាបាន ។

« នៅថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរ យើងប្រារព្ធពិធីដ៏រុងរឿង ដែលបានទន្ទឹងរង់ចាំយ៉ាងយូរអង្វែង ក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ។
វាជាថ្ងៃដែលបានផ្លាស់ប្ដូរអ្វីៗគ្រប់យ៉ាង ។
ជីវិតរបស់ខ្ញុំបានផ្លាស់ប្ដូរនៅថ្ងៃនោះ ។
ជីវិតរបស់បងប្អូនបានផ្លាស់ប្ដូរ ។
ជោគវាសនារបស់កូនចៅនៃព្រះបានផ្លាស់ប្ដូរ ។

ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ « អំណោយនៃព្រះគុណ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១០៧ ។

ECCE HOMO ដោយ ល្អីស ម៉ៃយ៉េ ទៅសារខេរ្វឹ រ៉ក






ឱ ព្រះវរបិតាអើយ ដោយ ស៊ីម៉ុន ឌើវ

**ការរងទុក្ខហួសពីការប្រៀបផ្ទឹមបាន**

« គ្មានចិត្តនៃជីវិតរមែងស្លាប់ណាអាចនឹកគិតដល់ទាំងស្រុងអំពីអ្វីដែលព្រះគ្រីស្ទបានធ្វើនៅក្នុងសួនគែតសេម៉ានីឡើយ ។

យើងដឹងថា ទ្រង់បានបង្ហូរព្រះលោហិតចេញពីគ្រប់រន្ធញើស នៅពេលដែលទ្រង់បានសោយនូវកាកនៃពែងល្វីងជូរចត់របស់ព្រះវរបិតាទ្រង់ដែលបានប្រទានដល់ទ្រង់ ។

យើងដឹងថាទ្រង់បានរងទុក្ខទាំងកាយ និងវិញ្ញាណ ហួសពីលទ្ធភាពដែលមនុស្សអាចទទួល លើកលែងតែជាការស្លាប់ប៉ុណ្ណោះ ។

យើងដឹងថាក្នុងពេលណាមួយ ដោយមិនប្រៀបធៀបនឹងយើងនោះឡើយថា ការឈឺចាប់របស់ទ្រង់នឹងធ្វើឲ្យឆ្អែតដល់ការទាមទារនៃសេចក្ដីយុត្តិធម៌ សង្គ្រោះដល់ដួងព្រលឹងដែលប្រែចិត្ត ពីការឈឺចាប់ និង ទារុណកម្មពីអំពើបាប ហើយធ្វើឲ្យសេចក្ដីមេត្តាករុណាមានចំពោះអ្នកទាំងឡាយណា ដែលជឿនៅក្នុងព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ ។

យើងបានដឹងថាទ្រង់បានក្រាបនៅលើដី នៅពេលដែលការឈឺចាប់ និងការឈឺពន់ពេកនៃបន្ទុកដ៏ខ្លាំងក្លាបានធ្វើឲ្យទ្រង់ញាប់ញ័រ ហើយធ្វើឲ្យទ្រង់មិនចង់សោយនូវពែងល្វីងឡើយ » ។

អែលឌើរ ប្រ៊ូស អរ ម៉ាក់ខនឃី ( ១៩១៥–៨៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « **The Purifying Power of Gethsemane** » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៥ ទំព័រ ៩ ។

**ការអនុវត្តផ្ទាល់ខ្លួន ៖** ទោះបីជាយើងពុំអាចដឹងពីវាជានិច្ចក្ដី ព្រះអង្គសង្គ្រោះរងការឈឺចាប់គ្រប់រូបភាពទាំងអស់អំឡុងពេលនៃដង្វាយធួន ។ ទ្រង់យល់អំពីការឈឺចាប់ខាងរូបកាយគ្រប់បែបយ៉ាងចាប់តាំងពីការបាក់ឆ្អឹងរហូតដល់ជំងឺរ៉ាំរ៉ៃដែលធ្ងន់ធ្ងរបំផុត ។ ទ្រង់ទទួលអារម្មណ៍នៃភាពអន្ទកាល និងក្ដីអស់សង្ឃឹមពីការឈឺចាប់ផ្លូវចិត្តដូចជា ការបាក់ទឹកចិត្ត ការថប់បារម្ភ ការញៀន ភាពឯកោ និងភាពសោកសៅ ។ ហើយទ្រង់ស្គាល់រសជាតិពីរបួសខាងវិញ្ញាណគ្រប់យ៉ាង ដោយសារទ្រង់បានលើកដាក់មកលើអង្គទ្រង់នូវអំពើបាបទាំងអស់នៃមនុស្សលោក ។

អែលឌើរ ដាវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « ក្នុងគ្រានៃភាពទន់ខ្សោយ យើងប្រហែលជាស្រែកទួញថា ‹ គ្មាននរណាយល់ឡើយ ។ គ្មាននរណាម្នាក់យល់ទេ › ។ ប៉ុន្តែព្រះរាជបុត្រានៃព្រះជ្រាបដឹង និងយល់ដ៏ឥតខ្ចោះ ដ្បិតទ្រង់បានដឹង និងបានទទួលបន្ទុករបស់យើងម្នាក់ៗ » ( « Bear Up Their Burdens with Ease » *Liahona* ខែ ឧសភា ២០១៤ ទំព័រ ៩០ ) ។